# ស្រណោះវាលស្រែ

១. ស្រណោះវាលស្រែ វាលស្រូវស្រុកខ្មែរ នាខែកក្ដិក
ព្រហាមស្រាងៗ ព្រះសូរ្យចោមព្រឹក ចែងចាំងរលឹក
ប្រជាមូលមី ។

២. វាលស្រែស្រូវទុំ ដូចកំរាលព្រហ្ម ក្រាលលើប្រតិពី
រស្មីពណ៌មាស ភ្លឺភ្លាសលាភី ស្រោពព្រះធរណី
លឿងទុំដូចមាស ។

៣. កក្ដិកស្រូវទុំ ព្រះពាយជួយនាំ ពិដោឈ្ងុយពាស
សព្វសាយទីឋាន លើលោកសន្និវាស ព្រះមេរុចោលភ្នាស
ផលបរិបូរ ។

៤. ពេលព្រះពាយផាត់ ព្រះមេរុរាសាត់ ដូចខ្សែទឹកហូរ
គយគន់គាប់ចិត្ត ប្រណិតពេញពោ សូរសៀងវាយោ
ជួយបក់រណ្ដំ ។

៥. ប្រហើរម្អមស្រែ ជួយថែមថយថៃ ក្រអូបរងំ
ក្លិនផ្សំផ្កាព្រៃ ពីនៃជើងភ្នំ ដូចទឹកអប់ផ្សំ
ពិដោធម្មជាតិ ។

៦. កណ្ដៀងលាស់ត្រួយ ចេញផ្កាមួយៗ លាយឡំស្មូកសៀត
ឯផ្កាត្រកួន ពួនសំងំឆ្លៀត បាំងកាយបញ្ចៀត
ក្នុងគល់កញ្ច្រាំង ។

៧. ក្នុងបឹងឯនាយ ផ្កាចា ធ្លាក់រាយ លាយនិងផ្កាវាំង
អណ្តែតរសាត់ កាត់ទឹកខែប្រាំង សារ៉ាយមកពាំង
បាំងផ្លូវបុប្ផា ។

៨. ទឹកបឹងថ្លាយង់ បើយកហត្ថក្បង់ លុបលាងភត្រា
ត្រជាក់ដល់ចិត្ត ហួសគិតឧបមា អោយចិត្តប្រាថ្នា
ចង់ហែបហែលលេង ។

៩. ផ្លែកណ្តឹងស្វា ពេលបានវាតា បោកបក់ប្រលែង
បញ្ចេញសូរសៀង ពិរោះជាងភ្លេង អោយចិត្តវង្វេង
ចងចាំមិនភ្លេច ។

១០. សូរសៀងសត្វយំ ពិរោះរងំ ដូចភ្លេងសារពេច
បំពេរអារម្មណ៍ បន្ទំជាល្បិច លួងលោមអោយភ្លេច
រឿងទុក្ខខ្លោចផ្សារ ។

១១. រសៀលជ្រោលជ្រេ ព្រះសូរ្យទន់ទេរ ទាបបាំងព្រឹក្សា
មាន់ទឹកស្រែកយំ បញ្ជាក់ប្រាប់ថា ព្រះសូរិយា
យាងយាត្រាលា ។

១២. ក្រវ៉ាន់ក្បែបឹង ចាប់ផ្តើមខំប្រឹង ជះក្លិនគន្ធា
ជាពេលព្រលប់ យប់យាងភាលា ក្នុងពេលសន្ធ្យា
នារាត្រីកាល ។

១៣. នេះនឹងស្រណោះ មិនអស់ចិត្តសោះ គ្រាធ្លាប់ត្រអាល
ស្រែកឃ្លានជំរក ធ្លាប់ជ្រកត្រកាល សាងសុខលើថ្នាល
មង្គល់ឧត្តម ។

**ដោយ សួន សេរីរដ្ឋា (ដែនដី សេរីភាព)**

អាមេរិក ២៤ វិច្ឆកា ២០០៦ (Thanks Giving’s Day)